**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៧ ស.សរ

# សេចក្ដីសំរេច

## ស្ដីពី

## ការបន្ថែមសមាសភាព ក្នុងក្រុមការងារ ដើម្បីរៀបចំឯកសារគតិយុត្ត និងពិនិត្យដោះស្រាយ ចំពោះគំរោងជួល និងអភិវឌ្ឍន៍កោះរុង និងកោះរុងសន្លឹម របស់ក្រុមហ៊ុន ISLAND DEVELOPMENT GROUP INC.

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្ដីពីការអនុវត្តន៍ច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្ដីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៧
- យោងសេចក្ដីសំរេចលេខ ២៩ សសរ ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០២ ស្ដីពីការបង្កើតក្រុមការងារ ដើម្បីរៀបចំឯកសារគតិយុត្ត និងពិនិត្យដោះស្រាយ ចំពោះគំរោងជួល និងអភិវឌ្ឍន៍កោះរុង និងកោះរុងសន្លឹម របស់ក្រុមហ៊ុន **ISLAND DEVELOPMENT GROUP INC.**
- យោងសេចក្ដីសំរេចលេខ ៣៦ សសរ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០០២ ស្ដីពីការបន្ថែមសមាសភាព ក្នុងក្រុមការងារ ដើម្បីរៀបចំឯកសារគតិយុត្ត និងពិនិត្យដោះស្រាយ ចំពោះគំរោងជួល និងអភិវឌ្ឍន៍កោះរុង និងកោះរុងសន្លឹម របស់ក្រុមហ៊ុន **ISLAND DEVELOPMENT GROUP INC.**
- អនុលោមតាមតំរូវការចាំបាច់

## សម្រេច

**ប្រការ១:** បន្ថែមសមាសភាព ឯកឧត្តម **ញ៉ឹម សុខា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាសមាជិក ០១រូបទៀត ក្នុងក្រុមការងារដើម្បីរៀបចំឯកសារគតិយុត្តិ និងពិនិត្យដោះស្រាយ ចំពោះគំរោងផ្លូល និងអភិវឌ្ឍន៍កោះរុង និងកោះរុងសន្លឹម ។

**ប្រការ២:** ក្រៅពីការបន្ថែមសមាសភាព ដូចមានចែងក្នុងប្រការ១ ខាងលើ ខ្លឹមសារនៃសេចក្តីសំរេចលេខ ២៩ សសរ ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០២ និងសេចក្តីសំរេចលេខ ៣៦ សសរ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០០២ នៅរក្សាទុកជាធរមានដដែល ។

**ប្រការ៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី - សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ - សហរដ្ឋមន្ត្រីក្រសួងការពារជាតិ - រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - រដ្ឋមន្ត្រីក្រសួងទេសចរណ៍ - រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ - រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន - រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ - រដ្ឋមន្ត្រីក្រសួងបរិស្ថាន -ប្រធាន "ក.អ.ក" - រដ្ឋមន្ត្រីគ្រប់ក្រសួង -ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះតាមភារកិច្ចរៀង១ខ្លួនអោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៣
- ឯកសារ-កាលប្បវត្តិ ✓